វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

ព្រឹត្តប័ត្រព័ត៌មានសង្ខេប

សប្តាហ៍ដែលបញ្ចប់
ថ្ងៃទី២៦ ខែកក្កដា ២០១៩

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺ៖

- ប្រទេសកម្ពុជា ជាអ្នកឈ្នះម្នាក់ នៅក្នុងសង្គ្រាមពាណិជ្ជកម្មរបស់លោកត្រាំ
- អ្នកនាំចូលចិនស្នើឱ្យលើកលែងពន្ធគយទៅលើទំនិញកសិកម្មរបស់អាមេរិក
- អ្នកនាំចូលរបស់អាមេរិកស្វែងរកមធ្យោបាយដើម្បីសម្របទៅនឹងការដាក់ពន្ធគយរបស់លោកត្រាំ

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗនៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារបណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

# ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

## ប្រទេសកម្ពុជា ជាអ្នកឈ្នះម្នាក់ នៅក្នុងសង្គ្រាមពាណិជ្ជកម្មរបស់លោក ត្រាំ

[បើយោងតាមទិន្នន័យចុងក្រោយរបស់អាមេរិក] ក្រុមហ៊ុនជាច្រើនកំពុងចាកចេញពីប្រទេសចិនទៅកាន់តំបន់អាស៊ីអាគ្នេយ៍ ដែលមានថ្លៃដើមទាប ហើយកម្ពុជាជាប្រទេសមួយដែលទទួលបានផលប្រយោជន៍ខ្ពស់ពីស្ថានភាពនេះ ។

ការនាំចូលប្រចាំឆ្នាំពីកម្ពុជា ទៅអាមេរិកបានកើនឡើងគួរឱ្យកត់សម្គាល់ក្នុងឆ្នាំ២០១៩ គឺកើនឡើង២០ %ក្នុងរយៈពេល៥ខែដំបូង គិតជាទឹកប្រាក់ ១,៨ ប៊ីលានដុល្លារ។

កម្ពុជាទទួលបាន លក្ខខណ្ឌក្នុងការចូលទៅកាន់ទីផ្សារអាមេរិក ដោយមិនបង់ពន្ធ ក្រោមប្រព័ន្ធអនុគ្រោះពន្ធទូទៅ (Generalized System of Preferences) ដែលជាកម្មវិធីមួយបង្កើតឡើងដើម្បីជំរុញកំណើនសេដ្ឋកិច្ចនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។

ទោះយ៉ាងណា ផលចំនេញមួយចំនួនដែលបានមកពីការនាំចេញអាចនឹងមាននៅលើក្រដាសតែប៉ុណ្ណោះ ដោយមានរបាយការណ៍ដែលបានបង្ហាញថា ក្រុមហ៊ុនផលិតរបស់ចិនកំពុងនាំទំនិញដែលផលិតនៅប្រទេសរបស់ខ្លួនដោយគ្រាន់តែឆ្លងកាត់តាមរយៈប្រទេសនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដើម្បីលាក់បាំងប្រភពប្រទេសដើមរបស់ផលិតផល។ ប្រទេសវៀតណាមបានសន្យាថានឹងចាត់វិធានការទៅលើការអនុវត្តបែបនេះ។

## តារាងប្រចាំសប្តាហ៍៖ កំណើនវិស័យសេវាកម្ម ចាប់ពីឆ្នាំ ២០១៨ ដល់ឆ្នាំ២០២០

តារាងនៅសប្តាហ៍នេះ បង្ហាញពីកំណើននៅក្នុងវិស័យសេវាកម្មរបស់ប្រទេសកម្ពុជា។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរំពឹងថាកំណើននៃវិស័យសេវាកម្ម ជាមធ្យមមានប្រមាណ ៦,៥% ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២០។ កំណើននេះត្រូវបានគេសន្មតថាដោយសារតែកំណើនពាណិជ្ជកម្មលក់ដុំ និងរាយ អចលនទ្រព្យ

សណ្ឋាគារ និងភោជនីយដ្ឋាន និងដឹកជញ្ជូន និងគមនាគមន៍ក្នុងឆ្នាំ២០១៩ និង២០២០ ។

| ឆ្នាំ | ២០១៨ | ២០១៩ប | ២០២០ព្យ |
|---|---|---|---|
| **វិស័យសេវាកម្មរួម** | **6.5%** | **6.7%** | **6.4%** |
| សណ្ឋាគារ និងភោជនីយដ្ឋាន | 5.7% | 5.6% | 5.6% |
| លក់ដុំ និងលក់រាយ | 6.6% | 6.8% | 6.8% |
| អចលនទ្រព្យ | 8.9% | 8.8% | 8.5% |
| ដឹកជញ្ជូន និងគមនាគមន៍ | 8.1% | 7.9% | 7.7% |

ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២០១៩

# ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

## អ្នកនាំចូលចិន ស្នើឱ្យមានការលើកលែងពន្ធគយទៅលើទំនិញកសិកម្មរបស់អាមេរិក

អាមេរិក និង ចិនបានប៉ះទង្គិចគ្នាទៅវិញទៅមកដោយការដាក់ទណ្ឌកម្មដែលគ្របដណ្តប់លើទំនិញពាណិជ្ជកម្មជាង ៣៦០ ប៊ីលានដុល្លា រចាប់តាំងពីប្រធានាធិបតី ដូណាល់ត្រាំ បានចាប់ផ្តើមសង្គ្រាមពាណិជ្ជកម្មកាលពីឆ្នាំមុន។ ថ្មីៗនេះ អ្នកនាំចូលរបស់ចិនបានស្នើទៅ រដ្ឋាភិបាលឱ្យលើកលែងពន្ធលើការនាំចូលទំនិញកសិកម្មមួយចំនួនពីអាមេរិក នេះបើយោងតាមសារព័ត៌មានរដ្ឋចិនដែលបានផ្សព្វផ្សាយយ៉ាងទូលំទូលាយនៅក្នុងសារព័ត៌មានធុរកិច្ច។

ការផ្លាស់ប្តូរនេះ អាចនឹងត្រូវបានការអនុញ្ញាតិបន្ទាប់ពី អាមេរិកបានដកចេញពន្ធលើទំនិញនាំចូលពីចិន ចំនួន ១១០មុខ ពីតារាងពន្ធគយរបស់ខ្លួន នៅដើមខែកក្កដា។

បន្ទាប់ពីកិច្ចប្រជុំកំពូល G20 អូសាកា លោកត្រាំ បានប្រកាសថាដើម្បីជាថ្នូរនឹងការសន្យារបស់ទីក្រុងវ៉ាស៊ីនតោន ក្នុងការព្យួរការដំឡើងពន្ធលើការនាំចូលរបស់ចិនចំនួន ៣០០ប៊ីលានដុល្លារអាមេរិក ទីក្រុងប៉េកាំងបានស្នើសុំទិញ "ផលិតផលស្បៀងអាហារ និងកសិកម្មយ៉ាងច្រើន" ពីអាមេរិក។

# សេដ្ឋកិច្ចពិភពលោក

## អ្នកនាំចូលរបស់អាមេរិក ស្វែងរកមធ្យោបាយដើម្បីសម្របទៅនឹងការដាក់ពន្ធគយរបស់លោកត្រាំ

ក្រុមហ៊ុននៅអាមេរិកកំពុងបង្កើនកិច្ចខិតខំប្រឹងប្រែងបន្ថែម ដើម្បីបង្វែរខ្សែសង្វាក់ផ្គត់ផ្គង់ចេញពីប្រទេសចិន ទៅបណ្តាប្រទេសជិតខាង បន្ទាប់ពីគោលនយោបាយពន្ធគយរបស់លោកត្រាំ។

ទិន្នន័យបង្ហាញថាបណ្តាក្រុមហ៊ុនក្នុងវិស័យមួយចំនួន ដូចជា៖ បច្ចេកវិទ្យា សម្លៀកបំពាក់ និងស្បែកជើង កំពុងនាំចេញទំនិញបន្ថែមទៀតពីប្រទេសកំពុងអភិវឌ្ឍន៍ដូចជាវៀតណាម និងម៉ាឡេស៊ី។

យោងតាមទិន្នន័យរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក ការនាំចេញកុំព្យូទ័រ និងគ្រឿងអេឡិចត្រូនិច ពីវៀតណាមទៅ អាមេរិកបានកើនឡើង ៧១,៦%ក្នុងរយៈពេល៥ខែដំបូងនៃឆ្នាំ២០១៩ បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។

# ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសំខាន់ៗនៅក្នុងសប្តាហ៍ខាងមុខនេះរួមមាន៖ សូចនាករសេដ្ឋកិច្ចសំខាន់ៗរបស់ប្រទេសវៀតណាមនៅថ្ងៃច័ន្ទ ក៏ដូចជាការសម្រេចចិត្តលើអត្រាការប្រាក់ នៅក្នុងប្រទេសជប៉ុន សហរដ្ឋអាមេរិក និងហុងកុង។

ខាងក្រោមនេះ ជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍដែលក្រុម FACT នឹងបន្តតាមដាននៅសប្តាហ៍ក្រោយ៖

ថ្ងៃច័ន្ទ ទី២៩ ខែកក្កដា

- ការលក់រាយរបស់ជប៉ុន នៅខែមិថុនា
- ផលិតកម្មឧស្សាហកម្មវៀតណាម នៅខែកក្កដា
- ការលក់រាយរបស់វៀតណាម នៅខែកក្កដា
- អតិផរណានៅវៀតណាម នៅខែកក្កដា

ថ្ងៃអង្គារទី ៣០ ខែកក្កដា

- ទំនុកចិត្តអាជីវកម្មរបស់កូរ៉េខាងត្បូង សម្រាប់ខែកក្កដា
- ភាពអត់ការងារធ្វើរបស់ជប៉ុន សម្រាប់ខែមិថុនា
- ផលិតកម្មឧស្សាហកម្មរបស់ជប៉ុន សម្រាប់ខែមិថុនា
- ការសម្រេចចិត្តលើអត្រាការប្រាក់របស់ធនាគារជប៉ុន

- ផ.ស.សរបស់បារាំង នៅឆមាសទី២ ឆ្នាំ២០១៩
- សមតុល្យថវិការបស់បារាំង សម្រាប់ខែមិថុនា
- ផលិតកម្មឧស្សាហកម្មរបស់ថៃ នៅខែមិថុនា

ថ្ងៃពុធ ទី៣១ ខែកក្កដា

- ផលិតកម្មឧស្សាហកម្មកូរ៉េខាងត្បូង នៅខែមិថុនា
- អតិផរណាអូស្រ្តាលី នៅឆមាសទី២ ឆ្នាំ២០១៩
- ទំនុកចិត្តអ្នកប្រើប្រាស់របស់ជប៉ុន នៅខែកក្កដា
- អតិផរណារបស់បារាំង នៅខែកក្កដា
- ការលក់រាយរបស់ថៃ នៅខែឧសភា

ថ្ងៃព្រហស្បតិ៍ ទី០១ ខែសីហា

- ការសម្រេចចិត្តលើអត្រាការប្រាក់របស់ធនាគាកណ្តាល អាមេរិក
- អតិផរណានៅកូរ៉េខាងត្បូងនៅខែកក្កដា
- តុល្យភាពពាណិជ្ជកម្មរបស់កូរ៉េខាងត្បូង នៅខែកក្កដា
- ការសម្រេចចិត្តអត្រាការប្រាក់ហុងកុង
- អតិផរណារបស់ឥណ្ឌូនេស៊ី នៅខែកក្កដា
- អតិផរណារបស់ថៃ នៅខែកក្កដា

ថ្ងៃសុក្រទី ០២ ខែសីហា

- ទំនុកចិត្តអាជីវកម្មប្រទេសថៃ នៅខែកក្កដា
- របាយការណ៍ប្រជុំគោលនយោបាយរូបិយវត្ថុរបស់ ធនាគារជប៉ុន
- ប្រាក់ឈ្នួលបុគ្គលិកមិនមែនកសិកម្ម របស់អាមេរិក នៅ ខែកក្កដា
- តុល្យភាពពាណិជ្ជកម្មរបស់អាមេរិកនៅខែមិថុនា
- និកម្មភាពរបស់របស់អាមេរិកនៅខែកក្កដា